# **ខ្លឹមសារសង្ខេបសាលដីកាតុលាការកំពូលលេខ៣៤** VIII (**២០២០**)

សាលដីកានេះអាចរកបាននៅ៖ SC.34(14.02.2020) (measboralaws.com)

**ពាក្យគន្លឹះ៖** គោលការណ៍មានសេរីភាពជានិច្ច, រំលោភលើទំនុកចិត្ត, កិច្ចសន្យារដ្ឋប្បវេណី, មូលដ្ឋានសម្រាប់ឃុំខ្លួន

## **១. អង្គហេតុនិងខ្លឹមសារសម្រេច**

ក្នុងឆ្នាំ២០១៧ មនុស្សមួយក្រុមបានមកបបួលជនរងគ្រោះដាក់ភាគហ៊ុន ចូលគ្នាទិញដីលក់យកចំណេញ (១៤ហិកតា មួយម៉ែត្រការ៉េ ២ទៅ៤ដុល្លា)។ ជនជាប់ចោទ ទទួលបានលុយហើយ ទិញបានតែដី២ហិកតា ក្នុងតម្លៃ១៣ដុល្លាក្នុង១ម៉ែត្រការ៉េ។ គាត់បាន ដាក់ឈ្មោះផ្សេង ថាជាម្ចាស់ដីលក់ឲ្យ។ អង្គហេតុនេះត្រូវបានចោទជាបទឆបោកនិងរំលោភលើទំនុកចិត្ត។ ជនត្រូវចោទត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន។

ចៅក្រមស៊ើបសួរបានសម្រេចមិនដោះលែងក្រៅឃុំតាមដីកាលេខ១៦០៥ ខែមិថុនាឆ្នាំ២០១៩។ ជនត្រូវចោទបានប្ដឹងឧទ្ធរណ៍។ សាលាឧទ្ធរណ៍ បានសម្រេចឲ្យនៅក្រៅឃុំ ដោយដាក់ក្រោមលក្ខខណ្ឌមួយចំនួនដូចជា មិនត្រូវផ្លាស់ប្ដូរលំនៅឋាន...(សាលដីកាលេខ៥៤ ខែកក្កដា ឆ្នាំ២០១៩)។ ជនរងគ្រោះ បានប្ដឹងសាទុក្ខប្រឆាំងនឹងសាលដីកាសម្រេចដោះលែងនៅក្រៅឃុំនេះ។

### **តុលាការកំពូល៖**

**២**-យល់ឃើញថា...ជូនដំណឹងដល់ភាគីទាំងពីរ តែមិនចូលខ្លួន...*តុលាការកំពូលមិនមានភាពចាំបាច់ស្ដាប់ចម្លើយជនត្រូវចោទទេ ចំពោះរឿងក្ដីនេះ ដូច្នេះតុលាការកំពូលអាចបន្តសវនាការបាន។*

**៣**-*យល់ឃើញថា..សាលាឧទ្ធរណ៍បានសម្រេចដោះលែងជនត្រូវចោទដោយសំអាងហេតុថា អង្គហេតុនៃការចោទប្រកាន់ចំពោះជនត្រូវចោទ ជាទំនាក់ទំនងគតិយុត្តនៃកាតព្វកិច្ចក្នុងកិច្ចសន្យារដ្ឋប្បវេណីដែលគូភាគី...បានព្រៀមព្រាងគ្នាដាក់ភាគហ៊ុន...ជនជាប់ចោទមានទីលំនៅនិងមុខរបរពិតប្រាកដ...ជាពិសេស..មានជំងឺប្រចាំកាយ...ដោយផ្អែកតាមគោលការណ៍ ជនត្រូវចោទត្រូវមានសេរីភាពជានិច្ច ដូចមានចែងក្នុងមាត្រា២០៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ...។*

**សម្រេច៖**...**២**-តម្កល់សាលដីកាលេខ៥៤...។

## **២. កំណត់សំគាល់**

**ក.** មកដល់ថ្ងៃចេញសាលដីកានេះ មានរយៈពេល៣ឆ្នាំ។

**ខ.** តុលាការកំពូលពិនិត្យមើលអង្គច្បាប់ តើសំអាងហេតុដោះលែងដោយសាលាឧទ្ធរណ៍ត្រឹមត្រូវឬទេ? ។ នេះជាសំខាន់ អនុលោមតាមមាត្រា២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ (មូលដ្ឋានសម្រាប់ឃុំខ្លួន)។

ភស្តុតាងបង្ហាញថា ជនត្រូវចោទមានមុខរបរនិងទីលំនៅ (គាត់មិនរត់គេច..)។ នេះបន្ថែមដោយសារថារឿងនេះ ទំនងជារឿងកិច្ចសន្យា ជាជាងរឿងព្រហ្មទណ្ឌ។ តុលាការក៏អនុលោមលើកត្តាដទៃទៀតដូចជាមនុស្សធម៌ (ជំងឺប្រចាំកាយត្រូវការព្យាបាលជាប្រចាំ)។ ទាំងនេះ នាំឲ្យមានការសម្រេចគាំទ្រដីកាដោះលែងនៅក្រៅឃុំ។ តុលាការបានយកគោលការណ៍មានសេរីភាពជានិច្ច (ការឃុំខ្លួនត្រូវតែជាការចាំបាច់) មកគាំទ្រផងដែរ។ នេះស្រដៀងនឹងសាលដីកាដទៃទៀតMeasboralaws។ សូមមើលបន្ថែមខ្លឹមសារសង្ខេបពាក់ព័ន្ធនឹងមូលដ្ឋានឃុំខ្លួន។